ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៥០ សរណ. ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពបាតុភូតធម្មជាតិ ក្នុងខែមេសា ឧសភា និងខែមិថុនា ឆ្នាំ ២០១៥

បន្ទាប់ពីបានធ្វើការតាមដាន វិភាគ និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែមដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន មេត្តាជ្រាបថា ៖

- ក្នុងពេលបច្ចុប្បន្ន ឥទ្ធិពលមូសុងឦសាន បានថយចុះជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះ កម្រិតសម្ពាធទាប បាន និងកំពុងគ្របដណ្តប់លើព្រះរាជាណាចក្រកម្ពុជា ទាំងមូល ។ បាតុភូតធម្មជាតិទាំងពីរខាងលើ បានជម្រុញឱ្យសីតុណ្ហភាពកើនឡើង ។
- សីតុណ្ហភាពកើនឡើង បានបង្កឱ្យមានគំនួចខ្យល់ទាំងនៅលើផ្ទៃដី និងក្នុងបរិយាកាស (Convect) ។ គំនួចខ្យល់ បានប្រមូលផ្តុំសំណើមក្នុងបរិយាកាស បង្កើតជាពពកដែលមានផ្ទុកចរន្តអគ្គិសនី ។

លក្ខខណ្ឌអាកាសធាតុ ដូចបានជម្រាបជូនខាងលើ បង្កើតឱ្យមានបាតុភូតរន្ទះ និងខ្យល់កន្ត្រាក់ នៅពេលមានភ្លៀងធ្លាក់ ។ បាតុភូតនេះ នឹងកើតមានច្រើន ក្នុងខែមេសា ឧសភា និងដើមខែមិថុនា ឆ្នាំ 2015 ពិសេស នៅតំបន់ទំនាបកណ្តាល ។

យោងលើស្ថានភាពអាកាសធាតុ ដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានលើស្ថានភាពអាកាសធាតុជាប់ជាប្រចាំ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែម ជាបន្តបន្ទាប់ក្នុងករណីចាំបាច់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh